00632241

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

F14/4/1

## អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 12 / 2010
ម៉ោង (Time/Heure): 11:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម **Motoo NOGUCHI**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agnieszka KLONOWIECKA MILART**
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម **Chandra Nihal Jayasinghe**
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០

**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

# សេចក្ដីសម្រេចផ្ដល់ឱកាសឲ្យសហមេធាវីការពារក្ដីជនជាប់ចោទ ឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា

SUPREME COURT CHAMBER CHAMBRE DE LA COUR
E.C.C.C * C.E.T.C

០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ: **F14/4/1**

**<u>សហព្រះរាជអាជ្ញា៖</u>**

ជា លាង

Andrew T. CAYLEY

**<u>ជនជាប់ចោទ៖</u>**

កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**<u>សហមេធាវីការពារក្ដីជនជាប់ចោទ៖</u>**

ការ សាវុត្ថ

កង ឫទ្ធារី

**<u>មេធាវីតំណាងភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១</u>**

ទី ស្រីនណា

Karim KHAN
Alain WERNER
Brianne McGONIGLE

**<u>មេធាវីតំណាងភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម២</u>**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

Silke STUDZINSKY

**<u>មេធាវីតំណាងភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣</u>**

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Annie DELAHAIE
Philippe CANONNE
Elizabeth RABESANDRATANA
Fabienne TRUSSES-NAPROUS
Christine MARTINEAU



SUPREME COURT CHAMBER * E.C.C.C * C.E.T.C. * CHAMBRE DE LA COUR SUPRÊME

00632243



**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“**អ.វ.ត.ក**”) បានទទួលចម្លើយតបរបស់សហព្រះរាជអាជ្ញា[1]( “ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ” ) ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” (“សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ”)។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក បានចេញសាលក្រមប្រឆាំងនឹងជនជាប់ចោទ(“សាលក្រមសាលាដំបូង”)[2]។ សហព្រះរាជអាជ្ញា ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១, ២ និង ៣ បានដាក់ពាក្យបណ្តឹងសាទុក្ខមកកាន់អង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសាលក្រមនេះ[3]។

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្កេកអ៊ាវហៅ “ឌុច” ប្រឆាំងនឹងសាលក្រមសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, F14/4។

[2] E188 (កែតម្រូវ)។

[3] “ បណ្តឹងសាទុក្ខបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ចំពោះការសម្រេចដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចេញពីសាលក្រម,” ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១០, F8; “បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ប្រឆាំងទៅនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០”, ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០, F9; “បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច”, ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១០, F10(“សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា”); “សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី(ក្រុម២) និងទឡ្ហីករណ៍បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម,” ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០, E188/12; “បណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសាលក្រម, សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២” ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០, F11; “បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមស្តីពីសំណងរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម២” ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០, F13; “សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០”, ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០, F14; សំណើសុំកែតម្រូវលើសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០, F14/Corr-1; សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០, F14/2 ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវី ឌុច ប្រឆាំងនឹងសាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០; និងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០, F14/4។



SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

00632244



២. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ត្រូវបានជូនដំណឹងទៅភាគីនានា។ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០ អង្គជំនុំជម្រះតុលាការកំពូល បានអនុញ្ញាតតាមសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេល១៥ថ្ងៃនៃប្រតិទិនក្នុងការដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ[4]។ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ ចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងទៅភាគីនានា។

## II. ច្បាប់ជាធរមាន

៣. វិធានផ្ទៃក្នុងចែងថា៖

> ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាពដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។
>
> ...
>
> លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុង និងស្របតាមសេចក្តីណែនាំអនុវត្ត ចៅក្រម អាចកំណត់ពេលវេលាសម្រាប់ការដាក់សារណា សេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរ និងឯកសារពាក់ព័ន្ធទៅនឹងសំណើសុំណាមួយ ឬ បណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ ដោយគិតពិចារណាដល់កាលៈទេសៈនៃរឿងក្តីនោះ ជាពិសេសក្នុងករណីដែលជនត្រូវចោទ ឬ ជនជាប់ចោទ ស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន[5]។

---

[4] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១០ F14/3; សំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេចអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០, ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០, F14/1។

[5] វិធាន ២១(១), ៣៩(២)នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៦)។



C.C.C * C.E.T.C * CHAMBER CHAMBRE DE LA COUR SUPRÊME

៤. ផ្នែកដែលពាក់ព័ន្ធនៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្មលើកទី ៥) ( "សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ" ចែងដូចខាងក្រោមថា៖

> លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ឬ សេចក្តីណែនាំអនុវត្តនេះ ឬ បទបញ្ជាពីអង្គជំនុំជម្រះនៃអ.វ.ត.ក សារណា និងពាក្យស្នើសុំ ត្រូវដាក់ទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះដែលត្រូវធ្វើចំណាត់ការជាមួយនឹងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប្រើប្រាស់ជាឯកសារយោង អនុលោមទៅតាមពេលវេលាកំណត់ដូចខាងក្រោម ហើយត្រូវបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន ៣៩ នៃវិធានផ្ទៃក្នុង ប្រសិនបើមានស្នើសុំពន្យាពេលកំណត់។
>
> អង្គជំនុំជម្រះអាចកំណត់អំឡុងពេលជាក់លាក់សម្រាប់ការដាក់ពាក្យស្នើសុំឬសារណា។
> ...
> ការឆ្លើយតបចំពោះចម្លើយតប នឹងត្រូវបានអនុញ្ញាតតែក្នុងករណីដែលមិនមានការស្នើសុំឱ្យមានការដេញដោលដោយផ្ទាល់មាត់ ហើយការឆ្លើយតបនេះ ត្រូវដាក់ក្នុងរយៈពេល០៥(ថ្ងៃ)នៃប្រតិទិន ដោយគិតចាប់ពីថ្ងៃជូនដំណឹង...នៃចម្លើយតបដែលភាគី ត្រូវឆ្លើយតប។
> ...
> ឯកសារដែលដាក់នៅ...អង្គជំនុំជម្រះតុលាការកំពូលនៃអ.វ.ត.ក មិនត្រូវឱ្យលើសពី ៣០ទំព័រជាភាសាអង់គ្លេស ឬ ភាសាបារាំង ឬ ៦០ទំព័រជាភាសាខ្មែរ លើកលែងតែមានបញ្ញត្តិចែងផ្ទុយពីនេះ នៅក្នុងវិធានផ្ទៃក្នុង ឬ សេចក្តីណែនាំអនុវត្ត ឬ បទបញ្ជាចេញដោយអ.វ.ត.ក[6]។

## III. ការសម្រេច

៥. ដោយហេតុថា វានឹងមាន"ការដេញដោលផ្ទាល់មាត់"លើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ទើបអង្គជំនុំជម្រះតុលាការកំពូល កត់សម្គាល់ឃើញថាមាត្រា៨(៤)នៃ

[6] មាត្រា៨(១), ៨(២), ៨(៤), ៥(២)។

សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ទំនងជាពុំរាប់បញ្ចូលការឆ្លើយតបជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញានោះទេ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះ យល់ឃើញថាមាត្រា៨(៤)មានលក្ខណៈចំណុះទៅនឹងមាត្រា៨(១)នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការកែប្រែទៅលើ "តារាងកាលវិភាគខាងក្រោម" នៃសារណា។

៦. វិធាន២១(១) នៃវិធានផ្ទៃក្នុង បានតម្រូវឱ្យអង្គជំនុំជម្រះ ធ្វើការបកស្រាយមាត្រា៨(៤)នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ"ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍...របស់ជនជាប់ចោទ"។ ដោយមានការការជំទាស់នៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការទទួលយកនៃសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ[7] អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាឱកាសក្នុងការដាក់ការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា នឹងជួយការពារផលប្រយោជន៍របស់ជនជាប់ចោទក្នុងការជំនុំជម្រះក្តីលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៧. លើសពីនេះ ឱកាសឆ្លើយតបសម្រាប់ជនជាប់ចោទទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា មានលក្ខណៈស្របជាមួយនឹងនីតិវិធីរបស់កម្ពុជា និងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ។ ក្នុងដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅចំពោះមុខតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌរបស់កម្ពុជា "គ្រប់ភាគីទាំងអស់ អាចដាក់ជូនសារណា ឬ សារណាថ្មីទៀតរហូតដល់បិទការពិភាក្សាដេញដោល"[8]។ ការឆ្លើយតបណាមួយចំពោះចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ គឺជាសិទ្ធិដែលត្រូវបានអនុញ្ញាតនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ូហ្វាន់ដា , តុលាការពិសេសសម្រាប់សេរ៉ាឡេអូន និងតុលាការពិសេសសម្រាប់លីបង់[9]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មានអំណាចក្នុងការអនុញ្ញាតឱ្យមានការឆ្លើយតបបែបនេះ ដើម្បីជាប្រយោជន៍នៃយុត្តិធម៌[10]។

[7] ចម្លើយតបរបស់សហព្រះជាអាជ្ញា កថាខណ្ឌ ៦-១០។

[8] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា(ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧), មាត្រា៤៣៤។

[9] វិធាននៃនីតិវិធីនិងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវី ICTY, IT/32/វិសោធនកម្មលើកទី៤៥(រួមបញ្ចូល



SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPRÊME

00632247



៨. ហេតុដូច្នេះ តាមការស្នើសុំរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូល សម្រេចផ្តល់ឱកាសឲ្យសហមេធាវីការពារក្តីជនជាប់ចោទ ដាក់ការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា។ ការឆ្លើយតបនេះ ប្រសិនបើត្រូវធ្វើ គួរគប្បីគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

ក. ការឆ្លើយតបនេះ អាចត្រឹមតែតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាប៉ុណ្ណោះ

ខ. ការឆ្លើយតបនេះ ត្រូវតែដាក់ក្នុងរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីការជូនដំណឹងនៃសេចក្តីសម្រេចនេះ និង

គ. ការឆ្លើយតបនេះ មិនអាចលើសពី៤០ទំព័រជាភាសាខ្មែរ ឬ ២០ទំព័រជាភាសាអង់គ្លេស ឬ ភាសាបារាំង[11]។

៩. នៅពេលដែលធ្វើការបដិសេធសំណើរបស់អង្គភាពគាំពារការការពារក្តីនៃអ.វ.ត.កសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាគូរភាគីក្នុងរឿងក្តី អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់ថា"ដោយហេតុថា ជនជាប់ចោទត្រូវបានតំណាងដោយសហមេធាវីជាតិពីររូប ដូច្នេះសមត្ថកិច្ចសមស្របរបស់អង្គភាពគាំពារការការពារក្តីក្នុងការបំពេញអណត្តិរបស់ខ្លួននោះ គឺផ្តល់ជំនួយ និងការគាំទ្រផ្នែកច្បាប់ដល់ជនជាប់ចោទ និងសហមេធាវី ដោយស្របទៅតាមវិធាន១១(២)(ញ)

---

វិសោធនកម្មចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០), វិធាន១១៣; វិធាននិងនីតិវិធីនៃភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិរ៉ូហ្វាន់ដារICTR (ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០), វិធាន១១៣; វិធាននៃនីតិវិធីនិងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសេរ៉ាឡេអូន SCSL (វិសោធនកម្មនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០), វិធាន១១៣ (A); និងវិធាននៃនីតិវិធីនិងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិលីបង់ STL/BD/2009/01/វិសោធនកម្មលើកទី៣(កែតម្រូវ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០), វិធាន១៨៤។

[10] បទបញ្ជាតុលាការ, ICC-BD/01-02-07, ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៤ (ធ្វើវិសោធនកម្ម) បទបញ្ជាតុលាការ ២៤(៥), ៦០(១)។

[11] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទកថាខណ្ឌ ៧ ("ភាសាដើម... គឺកំណត់តាមគោលបំណងនៃមាត្រា៥(២) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")។

នៃវិធានផ្ទៃក្នុង"[12]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល រំលឹកដល់សហមេធាវីការពារក្ដីជនជាប់ចោទថា អង្គភាពគាំពារការការពារក្ដី មានតួនាទីផ្ដល់"ជំនួយ និងការគាំទ្រផ្នែកច្បាប់" រួមបញ្ចូលទាំងការស្រាវជ្រាវផ្នែកច្បាប់ ការវិភាគ ការធ្វើសេចក្ដីព្រាង និងការផ្ដល់ប្រឹក្សា។

## IV. ផ្នែកសម្រេចសេចក្ដី

**យោងតាមមូលហេតុដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជាឯកច្ឆន្ទ៖**

១. ផ្ដល់ឱកាសឲ្យសហមេធាវីការពារក្ដីជនជាប់ចោទ ដាក់ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា។ ការឆ្លើយតបនេះ ប្រសិនបើត្រូវធ្វើ គួរគប្បីគោរពលក្ខខណ្ឌក្នុងកថាខណ្ឌ៨(ក)-(គ)ខាងលើ និង

២. ធ្វើការរំលឹកដល់សហមេធាវីការពារក្ដីជនជាប់ចោទនូវជំនួយ និងការគាំទ្រផ្នែកច្បាប់ដែលអង្គភាពគាំពារការការពារក្ដីអាចផ្ដល់ឲ្យ ដោយស្របតាមវិធាន១១(២)(ញ)នៃវិធានផ្ទៃក្នុង។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

SUPREME COURT CHAMBER CHAMBRE DE LA COUR SUPRÊME * E.C.C.C * C.E.T.C *

**គង់ ស្រ៊ឹម**

---

[12] សេចក្ដីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្ដីសុំដាក់សារណារបស់អ្នកដែលមិនមែនជាគូរភាគីក្នុងរឿងក្ដីមកកាន់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០ F7/2,កថាខណ្ឌ៩, សំណើរបស់អង្គភាពគាំពារការការពារក្ដីសុំដាក់សារណារបស់អ្នកដែលមិនមែនជាគូរភាគីក្នុងរឿងក្ដីមកកាន់អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ F7។